# សុន្ទរកថា
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ថ្លែងក្នុង
# ពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៣ និងលើកទិសដៅការងារ
# ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ

ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤

**- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី**

**- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ភ្ញៀវកិត្តិយស និងសមាជិក សមាជិកានៃ អង្គសន្និបាតទាំងមូល ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានបីតិសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមនៅក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៣ និងលើកទិសដៅការងារឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ នាឱកាសដ៏វិសេសវិសាលនេះ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ ទាំងនគរបាលជាតិ និងរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា គណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរួមសហការគ្នា ខិតខំថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សំដៅបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេស សម្រេចបាននូវសមិទ្ធផលនានាជាច្រើនក្នុងឆ្នាំ២០១៣ កន្លងមកនេះ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!**

ឆ្នាំ២០១៣កន្លងទៅនេះ យើងទាំងអស់គ្នាបានឆ្លងកាត់នូវព្រឹត្តិការណ៍ និងសភាពការណ៍សំខាន់ៗ ក្នុងដំណើរឈានឆ្ពោះទៅមុខប្រកបដោយសុទិដ្ឋិនិយមរបស់ប្រជាជាតិ និងប្រជាជនយើង។ កម្ពុជាបានចាត់ចែងរៀបចំបោះឆ្នោតជាតិលើកទី៥ តាមអាណត្តិដែលកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោត។ ដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅក្នុងបរិយាកាសដែលប្រទេសជាតិមានសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈយ៉ាងល្អប្រសើរ។ គណបក្សនយោបាយ ប្រជាពលរដ្ឋកម្ពុជា ពិសេសយុវជនយុវនារី អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយនានា និងអ្នកពាក់ព័ន្ធទាំងអស់បានចូលរួម

យ៉ាងសកម្មក្លៀវក្លាក្នុងដំណើរការបោះឆ្នោតទាំងមូលស្របតាមច្បាប់ បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត។ ទន្ទឹមនេះ យើងក៏សម្រេចបានដោយជោគជ័យក្នុងការតស៊ូខាងផ្លូវច្បាប់នៅតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេអំពីអធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជានៅតំបន់ជុំវិញប្រាសាទព្រះវិហារ ដែលជាការបង្ហាញច្បាស់នូវការប្តេជ្ញាចិត្តយ៉ាងប្តូរផ្តាច់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការថែរក្សា ការពារយ៉ាងគត់មត់នូវបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ។

ទន្ទឹមនឹងសមិទ្ធផលខាងលើនេះ យើងក៏ជួបប្រទះបញ្ហាប្រឈមខ្លះៗបណ្តាលមកពីការធ្វើបាតុកម្មទាមទារតវ៉ាពាក់ព័ន្ធលទ្ធផលនៃការបោះឆ្នោត ដែលបង្កប់ដោយគោលបំណងនយោបាយគ្រោងទុកជាមុន។ ដើម្បីបម្រើគោលបំណងនយោបាយនេះ ចលនានៃការធ្វើបាតុកម្មកូដកម្មរបស់កម្មកររោងចក្រ សហគ្រាស សកម្មជនដីធ្លី និងសកម្មជនសិទ្ធិមនុស្សមួយចំនួនក៏បានផ្ទុះឡើងព្រមៗគ្នា ហើយក្រុមជ្រុលនិយមក៏បានញុះញង់ អុចអាល បង្កឲ្យមានអំពើហិង្សាបណ្តាលឲ្យប៉ះពាល់ដល់អាយុជីវិតមនុស្ស ខូចខាតទ្រព្យសម្បត្តិសាធារណៈ ទ្រព្យសម្បត្តិឯកជន និងគម្រាមកំហែងដល់សន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសង្គម សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដែលចាប់បង្ខំឲ្យអាជ្ញាធរចាត់វិធានការស្របតាមច្បាប់ ដើម្បីស្តារឡើងវិញនូវសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម។

ព្រមជាមួយនេះ ក្នុងឆ្នាំ២០១៣កន្លងទៅនេះ កម្ពុជាយើងក៏បានជួបប្រទះនូវគ្រោះទឹកជំនន់យ៉ាងធ្ងន់ធ្ងរបណ្តាលឲ្យប៉ះពាល់ដល់អាយុជីវិតមនុស្ស ផលដំណាំរបស់ប្រជាជន ព្រមទាំងខូចខាតទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជនជាច្រើន ជាពិសេសនៅតំបន់ពាយព្យនៃប្រទេស។

ទោះបីជាជួបប្រទះបញ្ហាប្រឈមយ៉ាងណាក្តី ប៉ុន្តែយើងបានរួមគ្នាពុះពារជម្នះនូវបញ្ហាប្រឈមទាំងនេះ ដើម្បីបន្តថែរក្សា ពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសង្គម សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងខិតខំធានាប្រក្រតីភាព និងប្រសិទ្ធភាពនៃស្ថាប័នជាតិ រដ្ឋបាលសាធារណៈ ក៏ដូចប្រក្រតីភាពនៃជីវភាពសង្គមលើគ្រប់វិស័យ ជាហេតុធ្វើឲ្យកម្ពុជាយើងសម្រេចបានកំណើនសេដ្ឋកិច្ច ៧% តាមការរំពឹងទុក។

សមិទ្ធផលនយោបាយ សង្គម និងសេដ្ឋកិច្ចខាងលើនេះ មិនអាចកាត់ផ្តាច់បានពីការចូលរួមចំណែកយ៉ាងសកម្ម ពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ទាំងនគរបាលជាតិ និងរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា គណៈអភិបាល នៃរដ្ឋបាលថ្នាក់

ក្រោមជាតិ ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលក្នុងឱកាសនេះ ខ្ញុំសូមធ្វើការកត់សម្គាល់អំពីសមិទ្ធផលសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- កងកម្លាំងនគរបាលជាតិបានរួមសហការជាមួយអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនានា លើកកម្ពស់ស្មារតីទទួលខុសត្រូវក្នុងការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គមទាំងមូល ដើម្បីបង្កបរិយាកាសដល់ការអនុវត្តសិទ្ធិសេរីភាពខាងនយោបាយ សេរីភាពនៃការបញ្ចេញមតិ ដើរទន្ទឹមនឹងការលើកកម្ពស់ការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា។ ជាក់ស្តែង កងកម្លាំង នគរបាលជាតិ និងកងកម្លាំងមានសមត្ថកិច្ចនានា បានខិតខំរក្សាការពារសន្តិសុខ ក្នុងដំណើរការបោះឆ្នោតជាតិលើកទី៥ ឲ្យប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិភាព គ្មានការគម្រាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សានយោបាយកើតឡើងនោះឡើយ។

- ទន្ទឹមនេះ កងកម្លាំងនគរបាលជាតិបានសហការសម្របសម្រួលការពារសុវត្ថិភាពដល់ការធ្វើបាតុកម្ម កូដកម្មនានា ដើម្បីលើកស្ទួយសិទ្ធិសេរីភាពនៃការជួបជុំ ការបញ្ចេញមតិដោយសន្តិវិធី ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

- ទន្ទឹមនឹងការរ៉ាប់រងភារកិច្ចដ៏មមាញឹកខាងលើនេះ កងកម្លាំងនគរបាលជាតិបានខិតខំលើកកម្ពស់ប្រសិទ្ធភាពកិច្ចប្រតិបត្តិការក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសនានាក្នុងសង្គម លើមូលដ្ឋាននៃការលើកកម្ពស់កិច្ចសហការ និងការចូលរួមពីអ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋតាមរយៈការអនុវត្តជាប់ជាប្រចាំនូវគោលនយោបាយឃុំ ភូមិមានសុវត្ថិភាព ជាហេតុធ្វើឲ្យបទឧក្រិដ្ឋថយចុះមួយកម្រិតថែមទៀត បើប្រៀបនឹងឆ្នាំ២០១២កន្លងមកនេះ។ ព្រមជាមួយនេះ នគរបាលជាតិក៏បានបង្កើនកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសឆ្លងកាត់ដែនគ្រប់ប្រភេទបានកាន់តែមានប្រសិទ្ធភាព ពិសេសការបង្ការ ទប់ស្កាត់មិនឲ្យសកម្មភាពភេរវកម្មកើតមាននៅកម្ពុជាបានឡើយ។

- កងកម្លាំងនគរបាលជាតិបានសហការជាមួយកងយោធពលខេមរភូមិន្ទ ឈរជើងយ៉ាងរឹងមាំប្រកបដោយស្មារតីអង់អាចក្លាហាន ដើម្បីការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិ។ ក្នុងពេលដែលតុលាការយុត្តិធម៌អន្តរជាតិប្រកាសសេចក្តីសម្រេចបកស្រាយសាលក្រមពាក់ព័ន្ធអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជានៅតំបន់ជុំវិញប្រាសាទព្រះវិហារ កងកម្លាំងឈរជើងតាមព្រំដែនភាគខាងលិចបានបង្កើនស្មារតីប្រុងប្រយ័ត្ន ព្រមជាមួយការខិតខំរក្សាទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនៃព្រះរាជាណាចក្រថៃ សំដៅរក្សាស្ថិរភាព និង

ប្រក្រតីភាពនៃការចេញ ចូលឆ្លងកាត់ព្រំដែន ក៏ដូចការផ្លាស់ប្តូរទំនិញរវាងប្រជាពលរដ្ឋតាមតំបន់ព្រំដែននៃប្រទេសទាំងពីរ កម្ពុជា ថៃ។

- ចំពោះការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃបានខិតខំយកចិត្តទុកដាក់បន្តពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយអ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋាន ទាំងជាមួយក្រសួងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សង្គមស៊ីវិល ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍នានាដើម្បីរួមគ្នាបន្តការគាំទ្រ និងពង្រឹងបន្ថែមទៀត នូវស្ថាប័នអភិបាលកិច្ចថ្នាក់រាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ និងឃុំ សង្កាត់ ទាំងផ្នែកក្របខ័ណ្ឌច្បាប់ ធនធាន និងសមត្ថភាព ស្របតាមចក្ខុវិស័យ ដូចមានចែងនៅក្នុងកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង(ផអ៣)នៃកម្មវិធីជាតិនេះ។

- ក្រៅពីសមិទ្ធផលសំខាន់ៗខាងលើនេះ ក្រសួងមហាផ្ទៃក៏ខិតខំពុះពារសម្រេចបានសមិទ្ធផលនានាជាច្រើនទៀតក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ច តួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!**

ឆ្នាំ២០១៤នេះ ជាឆ្នាំដំបូងនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ដើម្បីយើងបន្តរួមគ្នាអភិវឌ្ឍសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដើរទន្ទឹមនឹងការលើកកម្ពស់នីតិរដ្ឋ។

ផ្អែកតាមសំណូមពរខាងលើនេះ ក្នុងឆ្នាំ២០១៤នេះ យើងត្រូវរួមគ្នាសម្រេចឲ្យបាននូវទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗចំនួនបី គឺ៖

**ទីមួយ៖** ត្រូវខិតខំរួមគ្នាការពាររដ្ឋធម្មនុញ្ញ ការពារឯករាជ្យភាព អធិបតេយ្យភាពដ៏ពេញលេញនៃព្រះរាជាណាចក្រកម្ពុជា ការពារ និងធានាឲ្យបាននូវប្រក្រតីភាពនៃស្ថាប័នជាតិរដ្ឋបាលសាធារណៈគ្រប់ថ្នាក់ និងបន្តលើកកម្ពស់ដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋនៅកម្ពុជា។

**ទីពីរៈ** បន្តថែរក្សា ពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងខិតខំលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ពិសេសការចូលរួមអនុវត្តគោលនយោបាយឃុំ ភូមិមានសុវត្ថិភាពឲ្យបានផុលផុសជាប់ជាប្រចាំ គ្រប់ច្រកល្ហកទូទាំងប្រទេស។

**ទីបីៈ** ធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាប្រចាំឆ្នាំ៧% ដោយប្រឹងប្រែងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុ គ្រប់គ្រងអតិផរណាឲ្យមានកម្រិតទាប ខិតខំប្រមូល និងគ្រប់គ្រងចំណូល ត្បិតត្បៀតការចំណាយដោយខិតខំប្រើប្រាស់ចំណាយឲ្យចំគោលដៅជាអាទិភាព និងបន្តគាំទ្រជំរុញផលិតកម្មគ្រប់ផ្នែក គ្រប់វិស័យក្នុងសង្គម។

លើមូលដ្ឋាននៃទិសដៅជាយុទ្ធសាស្ត្រទាំងបីខាងលើនេះ និងទិសដៅការងារឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ខ្ញុំសូមធ្វើការគូសបញ្ជាក់អំពីការងារជាអាទិភាពដែលក្រសួងមហាផ្ទៃ ត្រូវយកចិត្តទុកដាក់អនុវត្តក្នុងឆ្នាំ ២០១៤ នេះ ដូចខាងក្រោមៈ

**មួយៈ** កងកម្លាំងនគរបាលជាតិត្រូវសហការជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ខិតខំប្រមូលផ្តុំបង្កើនវិធានការប្រមូលព័ត៌មានដើម្បីវិភាគ និងវាយតម្លៃព័ត៌មាន ដែលទាក់ទងដល់សន្តិសុខជាតិ ឧបាយកលនានាដែលប៉ុនប៉ងបំផ្លិចបំផ្លាញសន្តិភាព ស្ថិរភាពនយោបាយ ការប៉ុនប៉ងបង្កឲ្យមានអំពើហិង្សា ភាពចលាចល វឹកវរក្នុងសង្គម សំដៅរួមគ្នាមានវិធានការប្រកបដោយប្រសិទ្ធភាព ក្នុងការបង្ការ ទប់ស្កាត់ និងចាត់វិធានការស្របតាមច្បាប់ជាធរមាន។

**ពីរៈ** ត្រូវខិតខំប្រឹងប្រែងបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយកងកម្លាំងមានសមត្ថកិច្ចនៃប្រទេសជិតខាង ប្រទេសក្នុងតំបន់ និងពិភពលោក ព្រមទាំងយន្តការថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីដាក់ចេញវិធានការប្រកបដោយប្រសិទ្ធភាព ក្នុងការបង្ការ ទប់ស្កាត់សកម្មភាពភេរវកម្មអន្តរជាតិ និងបទល្មើសឆ្លងកាត់ព្រំដែនគ្រប់ប្រភេទ ពិសេស សកម្មភាពចរាចរជួញដូរគ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មព័ត៌មានវិទ្យា។

**បីៈ** អំពីការប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ប្រភេទក្នុងសង្គម កងកម្លាំងនគរបាលជាតិ និងកងកម្លាំងមានសមត្ថកិច្ចនានាត្រូវសហការគ្នា ប្រកាន់យកវិធានការបង្ការ និងទប់ស្កាត់ជាចម្បង។ ហេតុនេះ ត្រូវរួមសហការគ្នាជាប្រព័ន្ធ ដើម្បីតាមដាន វិភាគវាយតម្លៃឲ្យបានស៊ីជម្រៅនូវការវិវត្តប្រែប្រួលរបស់សង្គម និងភាពចន្លោះប្រហោងរបស់យើង ក្នុងដំណើរការវិវត្តន៍ប្រែប្រួលនោះ ដូចជាការគ្រប់គ្រងមនុស្សនៅតាមភូមិសាស្ត្រ ឬតំបន់ដែលមានលក្ខណៈពិសេសខុសៗគ្នា ការគ្រប់គ្រងមុខសញ្ញា គ្រប់គ្រងមធ្យោបាយ យានយន្ត ឧបករណ៍សម្ភារនានា....។ល។

ទន្ទឹមនឹងការលើកកម្ពស់វិធានការជំនាញ ក៏ត្រូវយកចិត្តទុកដាក់លើកកម្ពស់ការចូលរួមពីសាធារណជនជាទូទៅ ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម។ ជារួម ចាប់តាំងពីការអនុវត្តគោលនយោបាយឃុំ ភូមិមានសុវត្ថិភាព រហូតមកទល់បច្ចុប្បន្ន យើងកត់សម្គាល់ឃើញថា កំណើននៃបទល្មើសនានាក្នុងសង្គមពីមួយឆ្នាំ ទៅមួយឆ្នាំមានអត្រាទាប បើប្រៀបនឹងកំណើននៃសកម្មភាពនានាក្នុងសង្គម រួមទាំងកំណើនប្រជាជនផង។ ហេតុនេះ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ កងនគរបាលជាតិ និងកងកម្លាំងមានសមត្ថកិច្ចនានា ត្រូវបន្តបំផុសជំរុញអនុវត្តគោលនយោបាយនេះ ឲ្យបានកាន់តែសកម្មផុលផុសជាប់ជាប្រចាំនៅគ្រប់មូលដ្ឋាន។

ទន្ទឹមនេះ កងកម្លាំងនគរបាលជាតិត្រូវលើកកម្ពស់ការគោរពវិន័យ និងមនសិការវិជ្ជាជីវៈ ត្រូវមានគុណធម៌ សីលធម៌ និងភាពស្មោះត្រង់ ស្អាតស្អំ ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ សំដៅបង្កើនការប្រាស្រ័យទាក់ទង ជំនឿ និងភាពកក់ក្តៅរបស់ប្រជាពលរដ្ឋ មកលើកងកម្លាំងនគរបាលជាតិ។

**បួន៖** ត្រូវបន្តខិតខំទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់នានាដែលប៉ះពាល់ដល់អាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជន។ ក្នុងនោះ គ្រោះថ្នាក់ចរាចរនៅតែជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរក្នុងសង្គម ដែលធ្វើឲ្យកម្ពុជាយើងក្លាយជាប្រទេសដែលមានគ្រោះថ្នាក់ចរាចរកម្រិតខ្ពស់ជាងបណ្តាប្រទេសនានាក្នុងតំបន់។ ហេតុនេះ ត្រូវលើកកម្ពស់កិច្ចសហការ ក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានសិក្សា អង្គការសង្គមស៊ីវិល ក្នុងការផ្សព្វផ្សាយអប់រំច្បាប់ចរាចរជើងគោក ដើរទន្ទឹមនឹងការពង្រឹងវិធានការដ៏មឺុងម៉ាត់ ក្នុងការអនុវត្តច្បាប់។ ទន្ទឹមនេះ ត្រូវពង្រឹងវិធានការគ្រប់គ្រងត្រួតពិនិត្យសុវត្ថិភាពយានយន្តគ្រប់ប្រភេទ ការអភិវឌ្ឍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក និងខិតខំរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ សោភ័ណភាពតាមដងផ្លូវក្នុងទីក្រុង ទីប្រជុំជន និងតាមដងផ្លូវជាតិនានាទូទាំងប្រទេស។

ចំពោះបញ្ហាអគ្គីភ័យ ខ្ញុំសូមថ្លែងនូវការកោតសរសើរ ចំពោះក្រសួងមហាផ្ទៃ និងអគ្គស្នងការនគរបាលជាតិ ដែលបានអនុវត្តអនុសាសន៍របស់ខ្ញុំ ក្នុងការកៀងគរឲ្យមានការចូលរួមរបស់ផ្នែកឯកជនក្នុងចលនាបង្ការ និងពន្លត់អគ្គីភ័យ។ ហេតុនេះ ត្រូវបន្តជំរុញ ពង្រឹងពង្រីកបទពិសោធន៍ និងសមិទ្ធផលនេះជាបន្តទៀត។ ព្រមជាមួយនេះ ត្រូវខិតខំបង្កើនការអប់រំដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋឲ្យម្ចាស់ការប្រុងប្រយ័ត្នក្នុងការបង្ការ និងសហការជួយសង្គ្រោះនៅពេលមានអគ្គីភ័យកើតឡើង។

**ប្រាំ៖** ត្រូវបន្តជំរុញកំណែទម្រង់នគរបាលជាតិ ទាំងក្របខ័ណ្ឌស្ថាប័ន ធនធានមនុស្ស និងមធ្យោបាយបំពេញការងារ។ ក្នុងក្របខ័ណ្ឌស្ថាប័ន ត្រូវធ្វើការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធចាត់ចែងការងារ តួនាទី ការទទួលខុសត្រូវរបស់អង្គភាពនគរបាលគ្រប់ថ្នាក់ ដើម្បីធ្វើការកែលម្អឲ្យបានសមស្របតាមតម្រូវការនៃការពង្រឹងសន្តិសុខជាតិ និងសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងការរីកចម្រើនរបស់ប្រទេសជាតិ។

ទន្ទឹមនេះ ត្រូវលើកកម្ពស់ការកសាង ពង្រឹងសមត្ថភាពធនធានមនុស្សក្នុងជួរកងកម្លាំងនគរបាលជាតិទាំងមូល ពិសេសត្រូវកសាងជួរនគរបាលវ័យក្មេងដើម្បីគោលដៅបន្តវេន។ ខិតខំពង្រឹងគុណភាពនៃការហ្វឹកហ្វឺនបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើរទន្ទឹមនឹងការលើកកម្ពស់ ការគោរពវិន័យ សីលធម៌វិជ្ជាជីវៈ និងភាពស្មោះត្រង់ ស្អាតស្អំ ក្នុងជួរកងកម្លាំងនគរបាលជាតិទាំងមូល។ ជាមួយនេះ ក៏ត្រូវធ្វើការត្រួតពិនិត្យ និងពង្រឹងការផ្គត់ផ្គង់មធ្យោបាយសម្ភារបច្ចេកទេស ដល់កងកម្លាំងនគរបាលជាតិ និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងភស្តុភារហិរញ្ញវត្ថុដល់អង្គភាពនគរបាលជាតិដែលកំពុងធ្វើប្រតិបត្តិការថែរក្សា ការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិ ក៏ដូចអង្គភាពប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម។ ខិតខំលើកកម្ពស់ការថែទាំសុខភាព និងជីវភាពរស់នៅដល់កងកម្លាំងនគរបាលជាតិទាំងមូល។ ជំរុញការបើកផ្តល់ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងរបបគោលនយោបាយផ្សេងៗដល់កងកម្លាំងនគរបាលជាតិឲ្យបានគ្រប់ចំនួនកំណត់ និងទាន់ពេលវេលា ដោយត្រូវលុបបំបាត់ឲ្យបានជាដាច់ខាតនូវការកាត់កងប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងរបបគោលនយោបាយផ្សេងៗ ដែលបានកំណត់។

**ប្រាំមួយ៖** បន្តជំរុញការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្របតាមគោលការណ៍នៃច្បាប់រៀបចំអង្គការ កម្មវិធីជាតិរយៈពេល១០ឆ្នាំ និងផែនការអនុវត្តកម្មវិធីជាតិនេះ។ ចាប់ពីឆ្នាំ២០១៤នេះតទៅ កំណែទម្រង់នេះបានឈានចូលក្នុងដំណាក់កាលកាន់តែស៊ីជម្រៅថែមទៀត នោះគឺជាដំណើរការផ្ទេរមុខងារ និងធនធានពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងបង្កិតការផ្តល់សេវា និងការអភិវឌ្ឍឲ្យទៅកៀកជិតប្រជាពលរដ្ឋ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឲ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយសមធម៌ សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការខុសៗគ្នានៃមូលដ្ឋាននីមួយៗ ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន។

ដំណាក់កាលកំណែទម្រង់ដ៏ស៊ីជម្រៅនេះនឹងមានផលប៉ះពាល់មកលើក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ ក៏ដូចរដ្ឋបាលថ្នាក់ក្រោមជាតិ។ ផលប៉ះពាល់ជាចម្បង គឺតួនាទី ការទទួលខុសត្រូវតាមវិស័យរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព័ន្ធផ្ទេរធនធានពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើតឲ្យមានប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងចាត់ចែងធនធានមនុស្ស ដែលកិច្ចការទាំងនេះតម្រូវឲ្យមានការពិនិត្យមើលឡើងវិញនូវច្បាប់ លិខិតបទដ្ឋានដែលមានជាធរមាន និងការតាក់តែងច្បាប់ លិខិតបទដ្ឋានថ្មីៗត្រូវធានាឲ្យមានសង្គតិភាពជាមួយច្បាប់រៀបចំអង្គការ និងប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ និងវិសហមជ្ឈការ។ ដំណើរការនេះទាមទារឲ្យមានការប្តេជ្ញាចិត្តខាងនយោបាយរយៈពេលវែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើរទន្ទឹមនឹងការតស៊ូជម្នះកែប្រែទម្លាប់ និងឥរិយាបថរបស់យើងក្នុងការគ្រប់គ្រង និងការចាត់ចែងការងារនៅគ្រប់ថ្នាក់ ដើម្បីជំរុញដំណើរការកែទម្រង់នេះ ឲ្យបោះជំហានទៅមុខជាបន្តទៀត។

ព្រមជាមួយនេះ ត្រូវរួមគ្នាគាំទ្រដល់កិច្ចដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាណត្តិទី២ ឲ្យប្រព្រឹត្តទៅក្នុងលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាព។

**ប្រាំពីរ៖** បន្តជំរុញ លើកកម្ពស់ការទទួលខុសត្រូវក្នុងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋឲ្យបានត្រឹមត្រូវតាមតម្លៃ និងរយៈពេលដែលបានកំណត់ និងត្រូវធ្វើការប្តេជ្ញាចិត្តរួមគ្នាលប់បំបាត់ឲ្យបានជាដាច់ខាតនូវការយកកម្រៃសេវាក្រៅពីការកំណត់ ដោយលើកកម្ពស់ ការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងការងារនេះ។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចនគរបាលជាតិត្រូវរៀបចំឲ្យមានយន្តការច្រកចេញ ចូលតែមួយក្នុងការផ្តល់សេវារដ្ឋបាល និងត្រូវរៀបចំឲ្យមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ ការទទួលព័ត៌មានត្រឡប់ និងពាក្យបណ្តឹងនានាពីអ្នកទទួលសេវា ព្រមទាំងរៀបចំយន្តការដោះស្រាយបណ្តឹង និងព័ត៌មានទាំងនោះប្រកបដោយតម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាព។

**ប្រាំបី៖** ត្រូវខិតខំបង្កើនកិច្ចសហការក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ ការទន្ទ្រានកាន់កាប់ព្រៃឈើ ដីធ្លីខុសច្បាប់ និងបទល្មើសនេសាទ ការដាក់ប៉ុស្តត្រួតពិនិត្យមិនស្របច្បាប់នៅគ្រប់មូលដ្ឋានទូទាំងប្រទេស។ ទន្ទឹមនេះ ត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយសំណើសំណូមពរ បញ្ហាប្រឈម និងភាពអសកម្មនានានៅមូលដ្ឋាន ដោយផ្អែកតាមគោល

ការណ៍ច្បាប់ ការចូលរួម ការពិគ្រោះយោបល់ តម្លាភាព លើមូលដ្ឋាននៃការលើកកម្ពស់សាមគ្គីភាព ការឃោគយល់ ការជួយឧបត្ថម្ភគាំទ្រទៅវិញទៅមកក្នុងចំណោមប្រជាជន និងសហគមន៍នានានៅគ្រប់មូលដ្ឋានទូទាំងប្រទេស។

ថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ដែលជាការធ្វើសកម្មភាពរបស់រាជរដ្ឋាភិបាលឆ្ពោះទៅមូលដ្ឋាន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កំពុងបន្តសហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីបញ្ជូនមន្ត្រីជាបន្ថែមទៀត។

អាស្រ័យហេតុនេះ ខ្ញុំសូមសំណូមពរដល់អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ សូមចូលរួម និងផ្តល់ការគាំទ្រ និងកិច្ចសហការជាមួយក្រុមការងារនេះឲ្យសម្រេចបាននូវបេសកកម្មរបស់ខ្លួននៅគ្រប់មូលដ្ឋានទូទាំងប្រទេស។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!**

ខាងលើនេះ ជាអនុសាសន៍សំខាន់ៗមួយចំនួន សំដៅបំពេញបន្ថែមក្នុងទិសដៅអនុវត្តការងារឆ្នាំ២០១៤នេះ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងមហាផ្ទៃ ទាំងរដ្ឋបាលស៊ីវិល និងនគរបាលជាតិ ក៏ដូចក្រុមប្រឹក្សា គណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធទាំងអស់នឹងបន្តរួមសាមគ្គីជាធ្លុងមួយ ដើម្បីអនុវត្តសម្រេចឲ្យបានជោគជ័យនូវទិសដៅ ភារកិច្ចសំខាន់ៗក្នុងឆ្នាំ២០១៤ ដែលជាការចូលរួមចំណែកអនុវត្តនូវកម្មវិធីនយោបាយនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីបន្តជំរុញឲ្យប្រទេសជាតិរបស់យើងមានការរីកចម្រើនលើគ្រប់វិស័យប្រកបដោយចីរភាព និងវិបុលភាព។

ចុងបញ្ចប់នេះ ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រកាសបិទសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៣ និងលើកទិសដៅការងារឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃនៅពេលនេះ និងសូមជូនពរគណៈអធិបតី ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាភ្ញៀវកិត្តិយស និងសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**